ក្រសួងយុត្តិធម៌
លេខ ២៨០ ព្រ.ទ-៩៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

**លោក ប្រធានតុលាការ ខេត្ត ក្រុង**

**លោកព្រះរាជអជ្ញាអមតុលាការ ខេត្ត ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** សេចក្តីណែនាំអំពីចំណាត់ការលើសំណុំរឿងបទល្មើសព្រៃឈើ ។

ខ្ញុំសូមជម្រាបអស់លោកថា នៅពេលកន្លងទៅថ្មីៗនេះ ក្រសួងយុត្តិធម៌បានទទួលលិខិតផ្ញើនៗពីក្រសួងកសិកម្មរុក្ខាប្រមាញ់ស្តីពីតុលាការ ខេត្ត-ក្រុង មួយចំនួនពុំព្រមលើកយកសំណុំរឿងបទល្មើសព្រៃឈើមកជំនុំជម្រះឲ្យបានទទាន់ពេលវេលា ។

បញ្ហានេះ ក្រសួងបានពិនិត្យឃើញថា មានសំណុំរឿងបទល្មើសព្រៃឈើខ្លះមាននៅសល់តាំងពីឆ្នាំ ១៩៨០ មកម្ល៉េះ ដែលតុលាការ ខេត្ត-ក្រុងមួយចំនួនពុំបានលើកយកមកធ្វើការជំនុំជម្រះ ។

ដើម្បីជៀសវាងកុំអោយមានការកកស្ទះសំណុំរឿងប្រភេទនេះតទៅទៀត ក្រសួងសូមលោកប្រធានតុលាការ និងព្រះរាជអាជ្ញាអមតុលាការ ខេត្ត-ក្រុង លើកយកសំណុំរឿងបទល្មើសព្រៃឈើដែលមាននៅសល់ទាំងប៉ុន្មានមកធ្វើការជំនុំជម្រះអោយឆាប់ ។ បើសំណុំរឿងទាំងនោះពុំទាន់មានធាតុផ្សំគ្រប់គ្រាន់នៅឡើយទេ គួរបង្វិលសំណុំរឿងទាំងនោះទៅអោយនាយកដ្ឋានរុក្ខាប្រមាញ់ ដើម្បីស៊ើបអង្កេតបំពេញបន្ថែមអោយបានគ្រាប់ជ្រុងជ្រោយជាបន្ទាន់រួចហើយចាត់ការតាមច្បាប់តទៅ ។

ចំពោះបទល្មើសជលផល និងគយក៏ត្រូវអនុវត្តអោយបានទាន់ពេលដូចការណែនាំនេះដែរ ។

តែបើតុលាការបានអញ្ជើញតំណាងក្រសួងកសិកម្ម និងរុក្ខាប្រមាញ់ចូលមកតុលាការ ដើម្បីចាត់ការរឿងនោះហើយពុំមានតំណាងជាមួយចូលមកទេ ដែលជាមូលហេតុនាំអោយរឿងនៅកកស្ទះនោះសូមរាយការណ៍មកក្រសួយុត្តិធម៌ដើម្បីក្រសួងយុត្តិធម៌ជម្រាបទៅក្រសួងពាក់ព័ន្ធ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៤

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

ចម្លងជូន
- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- ក្រសួងកសិកម្មរុក្ខាប្រមាញ់
- ដើម្បីជ្រាបជាព័ត៌មាន